# ចេតសិក៥២ តាមលំដាប់អក្ខរក្រម

| លេខរៀង | ឈ្មោះចេតសិក |
|---|---|
| ១ | ករុណាចេតសិក (ករុណាសត្វមានទុក្ខ មានការមិនបៀតបៀន) |
| ២ | កាយកម្មញ្ញតាចេតសិក (កាយដែលគួរដល់ការងារនៃសោភណធម៌) |
| ៣ | កាយបស្សទ្ធិចេតសិក (ស្ងប់រម្ងាប់ មិនរាយមាយក្នុងកាយ  - បដិបក្ខនឹងឧទ្ធច្ច) |
| ៤ | កាយបាគុញ្ញតាចេតសិក (កាយដ៏ស្ទាត់ជំនាញធ្វើឲ្យចេតសិក ទាំង ឡាយដែលកើតរួមជាមួយ ស្ទាត់ជំនាញក្នុងធម៌ល្អផូរផង់) |
| ៥ | កាយមុទុតាចេតសិក (ទន់ភ្លន់ ធ្វើឲ្យចេតសិកទាំងឡាយ កើតរួម ជាមួយ មិនគ្រោតគ្រាត - បដិបក្ខជាមួយទិដ្ឋិនិងមានចេតសិក) |
| ៦ | កាយលហុតាចេតសិក (ស្រាលកាយព្រោះប្រកបដោយកុសល - មិនធ្ងន់ដូចអកុសល - បដិបក្ខនឹងថីន និងមិទ្ធ) |
| ៧ | កាយុជុកតាចេតសិក (ភាវនៃកាយស្មោះត្រង់ មិនវៀចវេរ មិនឆ បោក ប្រាថ្នាត្រង់ ចំពោះធម៌ដែលល្អផូរផង់) |
| ៨ | កុក្កុច្ចចេតសិក (រោលរាលរំខានចិត្ត ស្តាយចិត្តក្នុងអកុសល ដែលបានធ្វើហើយ និងក្នុងកុសលដែលមិនទាន់បានធ្វើ) |
| ៩ | ចិត្តកម្មញ្ញតាចេតសិក (ចិត្តគួរដល់ការងារនៃសោភណធម៌) |
| ១០ | ចិត្តបស្សទ្ធិចេតសិក (ចិត្តកើតរួមជាមួយការស្ងប់ ចិត្តនោះប្រព្រឹត្តទៅ ក្នុងទានសីល ភាវនា - បដិបក្ខនឹងឧទ្ធច្ច) |
| ១១ | ចិត្តបាគុញ្ញតាចេតសិក (ស្ទាត់ជំនាញធ្វើឲ្យចិត្ត ទាំងឡាយដែលកើត រួមជាមួយ ស្ទាត់ជំនាញក្នុងធម៌ល្អផូរផង់) |
| ១២ | ចិត្តមុទុតាចេតសិក (ទន់ភ្លន់ ធ្វើឲ្យចិត្តទាំងឡាយ កើតរួមជាមួយ មិនគ្រោតគ្រាត - បដិបក្ខជាមួយទិដ្ឋិនិងមានចេតសិក) |
| ១៣ | ចិត្តលហុតាចេតសិក (ធ្វើឲ្យចិត្តដែលកើតរួមមិនធ្ងន់  - បដិបក្ខនឹងថីន និងមិទ្ធ) |
| ១៤ | ចិត្តុជុកតាចេតសិក (ធ្វើឲ្យចិត្តស្មោះត្រង់ មិនវៀចវេរ ប្រាថ្នាត្រង់ ចំពោះធម៌ដែលល្អផូរផង់) |
| ១៥ | ចេតនាចេតសិក (ចេតនាចេតសិក ជាកម្មបច្ច័យ ឬ ជាធម្មជាតិសន្សំ បុណ្យនិងបាប) |
| ១៦ | ឆន្ទចេតសិក (សភាពធ្វើចិត្តឲ្យប្រាថ្នានូវអារម្មណ៍) |
| ១៧ | ជីវិតិន្ទ្រិយចេតសិក (តម្រង់រក្សាសម្បយុត្តធម៌ឲ្យតម្រង់ជីវិត តាំងនៅ ត្រឹមមួយជួរខណៈ មុននឹងរលត់ទៅ) |
| ១៨ | តត្រមជ្ឈត្តតាចេតសិក (ជាកណ្តាលមិនលំអៀង ប្រាសចាកអគតិ ព្រងើយកន្តើយក្នុង សត្វនិងសង្ខារ - ជាផ្នែក១នៃឧបេក្ខាទាំង១០) |

| | |
|---|---|
| ១៩ | ថីនចេតសិក (ធ្វើចិត្តឲ្យរួញរា អស់កម្លាំង មិនខ្វល់ខ្វាយ) |
| ២០ | ទិដ្ឋិចេតសិក (ឃើញខុស យល់ខុសក្នុងសភាវធម៌ ទើបធ្វើឲ្យប្រកាន់ មាំ ក្នុងវត្តប្រតិបត្តិដែលមិនត្រឹមត្រូវតាមហេតុផលនៃសភាវធម៌) |
| ២១ | ទោសចេតសិក (សភាវដែលប្រទូស្តនឹងអារម្មណ៍ ក្តៅក្តួលមួម៉ៅ) |
| ២២ | បញ្ញិន្ទ្រិយចេតសិក (ឃើញត្រូវ យល់ត្រូវក្នុងសភាវធម៌និង ហេតុផល - បញ្ញាជាធំជាង សហជាតធម៌ទាំងពួង) |
| ២៣ | បីតិចេតសិក (ធម្មជាតិធ្វើកាយនិងចិត្តឲ្យឆ្អែត កើតរួមជាមួយនឹងសោមនស្ស វេទនាប៉ុណ្ណោះ) |
| ២៤ | ផស្សចេតសិក (កើតឡើងខ្ទប់អារម្មណ៍ណា ក៏ជាបច្ច័យឲ្យចិត្តនិង ចេតសិកដទៃៗ ដែលកើតរួមគ្នាក្នុងខណៈនោះ ធ្វើកិច្ចការតាម នាទីនៃចិត្តនិង ចេតសិកនោះៗ) (អារម្មណ៍៦ ទ្វារ៦) |
| ២៥ | មនសិការចេតសិក (ធ្វើទុកក្នុងចិត្ត យកចិត្តទុកដាក់ក្នុងអារម្មណ៍) |
| ២៦ | មានចេតសិក (ប្រកាន់ខ្លួន លើកដំកើងខ្លួន) |
| ២៧ | មច្ឆរិយចេតសិក (កំណាញ់សម្បត្តិរបស់ខ្លួន មិនចង់ឲ្យបុគ្គលដទៃ មានចំណែករួម ប្រើប្រាស់ទទួលប្រយោជន៍ ពីសម្បត្តិនោះ) |
| ២៨ | មិទ្ធចេតសិក (ធ្វើឲ្យ ងងុយងោកងក់ ខ្សោយកម្លាំង) |
| ២៩ | មុទិតាចេតសិក (ត្រេកអរដល់សត្វ ដែលដល់នូវសេចក្តីសុខ) |
| ៣០ | មោហចេតសិក (មិនដឹងលក្ខណៈនៃសភាវធម៌ តាមសេចក្តីពិត) |
| ៣១ | លោភចេតសិក (ជាប់ជំពាក់ ប្រាថ្នាត្រូវការអារម្មណ៍) |
| ៣២ | វិចារចេតសិក (ផ្គងតាមវិតក្ក មិនថាឡើយ វិតក្កនឹងត្រិះរិះយ៉ាងណា វិចារចេតសិកក៏ផ្គងតាមយ៉ាងនោះ) |
| ៣៣ | វិចិកិច្ឆាចេតសិក (ស្ទាក់ស្ទើរ សង្ស័យ មានចម្ងល់ក្នុងលក្ខណៈនៃ នាមធម៌ រូបធម៌ អរិយសច្ចធម៌ ព្រះរតនត្រ័យ...) |
| ៣៤ | វិតក្កចេតសិក (ត្រិះរិះក្នុងអារម្មណ៍ដែលផស្សចេតសិកប៉ះខ្ទប់) |
| ៣៥ | វិរិយចេតសិក (គាំទ្រជ្រោមជ្រែង សហជាតិធម៌មិនឲ្យរួញរា) |
| ៣៦ | វេទនាចេតសិក (កើតនឹងចិត្តគ្រប់ដួង កើតរួមនឹងចិត្តក្នុងខណៈនោះ ក៏ ដឹងខ្លួនសប្បាយ សុខ ទុក្ខ ឬព្រងើយ ក្នុងអារម្មណ៍នោះ |
| ៣៧ | សញ្ញាចេតសិក (ចងចាំ សំគាល់អារម្មណ៍ ដែលប្រាកដបន្តជារឿងរ៉ាវ |
| ៣៨ | សតិចេតសិក (រលឹកបានក្នុងកុសលទាំងឡាយមានទាន សីលភាវនា) |
| ៣៩ | សទ្ធាចេតសិក (បរិសុទ្ធជ្រះថ្លាស្អាតក្នុងកុសលធម៌ ធ្វើឲ្យអកុសលធម៌ ទាំងឡាយ កើតឡើងមិនបាន) |
| ៤០ | សម្មាកម្មន្តចេតសិក (ធ្វើកិច្ចវៀរចាកនូវកាយទុច្ចរិត៣ គឺ បាណាតិបាត អទិន្នាទាន និងកាមេសុមិច្ឆាចារ) |

| | |
|---|---|
| ៤១ | សម្មាវាចាចេតសិក (ធ្វើកិច្ចវៀរចាកនូវវចីទុច្ចរិត៤ គឺ មុសាវាទ បិសុណាវាចា ផរុសវាទ សម្ផប្បលាបវាចា) |
| ៤២ | សម្មាអាជីវចេតសិក (ធ្វើកិច្ចវៀរចាកនូវកាយទុច្ចរិត៣ និងវចីទុច្ចរិត៤ ដែលជាមិច្ឆាជីវៈ) |
| ៤៣ | ហិរិចេតសិកិ (ខ្មាស់ខ្ពើមអកុសលធម៌ ប្រៀបបានទៅនឹងការខ្ពើម ដោយមិនចាប់កាន់របស់មិនស្អាត) |
| ៤៤ | អទោសចេតសិក (មិនមួរម៉ៅ មិនគ្រោតគ្រាតប្រទូស្ត មានលក្ខណៈ អាការជាមិត្រ មេត្រីភាព-មេត្តា) |
| ៤៥ | អធិមោក្ខចេតសិក (ធ្វើចិត្តអោយតាំងចុះណែនក្នុងអារម្មណ៍) |
| ៤៦ | អនោត្តប្បចេតសិក (មិនតក់ស្លុត មិនភ័យខ្លាចចំពោះអកុសលធម៌) |
| ៤៧ | អលោភចេតសិក (មិនជាប់ជំពាក់ក្នុងអារម្មណ៍) |
| ៤៨ | អហិរិកចេតសិក (មិនខ្មាស់ មិនខ្ពើមអកុសលធម៌) |
| ៤៩ | ឥស្សាចេតសិក (ប្រណែន ឫស្សានឹងទ្រព្យសម្បត្តិ រូបសម្បត្តិ និង គុណសម្បត្តិអ្នកដទៃ) |
| ៥០ | ឱត្តប្បចេតសិក (តក់ស្លុតភ័យខ្លាច នូវទោសរបស់អកុសលធម៌) |
| ៥១ | ឧទ្ធច្ចចេតសិក (រាយមាយ មិនស្ងប់ក្នុងអារម្មណ៍) |
| ៥២ | ឯកគ្គតាចេតសិក (តាំងមាំក្នុងអារម្មណ៍ ផ្ចង់ចិត្តឲ្យមានអារម្មណ៍តែ១) |